ខ្លឹមសារសង្ខេបសាលដីកាតុលាការកំពូលលេខ៤២ (២០២០)

សាលដីកានេះអាចរកបាននូវ៖ សាលដីកាតុ.កំពូលលេខ៤២(រំលោភលើទំនុកចិត្ត)

**ពាក្យគន្លឹះ៖** ៖ រំលោភលើទំនុកចិត្តពិសេស, ការបដិសេធមិនមើលអង្គហេតុ, សមគំនិត

## ១. អង្គហេតុនិងខ្លឹមសារសម្រេច

ខែកក្កដា ឆ្នាំ២០១៥ ប្រធានសាខាធនាគារ បានអនុម័តកម្ចីឲ្យប្រពន្ធខ្លួនជាច្រើនលើកនិងផ្តល់ឥណទានសម្រាប់គ្រួសារនីមួយៗ ដែលខុសនឹងគោលការណ៍ធនាគារ។ ធនាគារ បានកោះហៅមកពិភាក្សា តែគាត់មិនព្រមចូលខ្លួន។

អង្គហេតុនេះ ត្រូវបានចោទជាបទរំលោភលើទំនុកចិត្តពិសេសដោយអភិបាល តាមមាត្រា៣៩៣នៃក្រមព្រហ្មទណ្ឌនិងចោទប្រកាន់ប្រពន្ធគាត់ពីបទសមគំនិតក្នុងបទនេះ។ សាលាដំបូងរាជធានីភ្នំពេញបានផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារ២ឆ្នាំនិងពិន័យបួនលានរៀល ជនជាប់ចោទជាប្រពន្ធដាក់គុក២ឆ្នាំ។ ទាំងពីរនាក់រួមគ្នាសងជំងឺចិត្ត ២០លានរៀល (សាលក្រមលេខ៥៨៦ ខែមីនា ឆ្នាំ២០១៧)។ សាលាឧទ្ធរណ៍បានតម្កល់សាលក្រម ដោយបន្ថែមជំងឺចិត្តដល់៤០លានរៀល (សាលដីកាលេខ២៦ ខែមីនា ឆ្នាំ២០១៩)។ ជនជាប់ចោទទាំងពីរបានប្តឹងសាទុក្ខក្នុងខែមីនា ឆ្នាំ២០១៩។

### តុលាការកំពូល

យល់ឃើញ៖...តុលាការកំពូលបានជូនដំណឹង២ដងទៅជនជាប់ចោទឲ្យដាក់សារណាការពារ ក៏ប៉ុន្តែមិនបានធ្វើសារណាការពារ។ ២-...*ដូច្នេះ អនុលោមតាមស្មារតីមាត្រា៤៣៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលពុំអាចសម្រេចលើបញ្ហាច្បាប់ ដែលអ្នកប្តឹងសាទុក្ខ ពុំបានសរសេររៀបរាប់ក្នុងសារណារបស់ខ្លួននោះទេ។*

### សម្រេច

១. បដិសេធបណ្តឹងសាទុក្ខ...២. តម្កល់សាលដីកាលេខ២៦...។

## ២. កំណត់សំគាល់

**ក.** មកដល់ថ្ងៃសវនាការនៃតុលាការកំពូល មានរយៈពេល៥ឆ្នាំ។ **ខ.** មាត្រា២៩(៣)នៃក្រមព្រហ្មទណ្ឌចែងថា *អ្នកសមគំនិតនៃបទឧក្រិដ្ឋឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ* ។ ក្នុងរឿងនេះសាលាដំបូងបានសម្រេចផ្តន្ទាទោសចារីនិងអ្នកសមគំនិតទោសដូចគ្នា (២ឆ្នាំក្នុងពន្ធនាគារ)។ ទោះបីជាយ៉ាងនេះក្តី សាលក្រមខ្លះដាក់ទោសចារីនិងអ្នកសមគំនិតខុសគ្នា។ **គ.** តំណាងមហាអយ្យការអមតុលាការកំពូល អះអាងថាប្រពន្ធរបស់ចារី *បានសងលុយហើយ ពុំមានការខូចខាតនោះទេ ពុំមានបទល្មើស។*

*...ការសម្រេចឲ្យខ្ចីខុសគោលការណ៍ ហើយមានការខូចខាត គប្បីឲ្យឈ្មោះ...ទទួលខុសត្រូវក្នុងរឿងរដ្ឋប្បវេណី។* **ឃ.** ក្នុងការពិចារណាទទួលយកបណ្តឹងសាទុក្ខ តុលាការកំពូលពិនិត្យមើលថាបណ្តឹងធ្វើឡើងក្នុងពេលកំណត់ (មាត្រា៤២០) និងចូលក្នុងមូលដ្ឋានមាត្រា៤១៩នៃក្រមនីតិវិធីព្រហ្មទណ្ឌឬទេ? អ្នកប្តឹងសាទុក្ខ ត្រូវបានស្នើឲ្យដាក់នូវសារណាការពារ។ ការដាក់ឬមិនដាក់ មិនមែនជាមូលដ្ឋានបដិសេធបណ្តឹងសាទុក្ខទេ។ ក្នុងរឿងនេះ អ្នកប្តឹងអវត្តមាន ហើយមិនបានដាក់សារណាការពារ ដែលតុលាការកំពូលពិបាកនឹងដឹងបញ្ហាផ្លូវច្បាប់ ទើបសម្រេចមិនពិចារណា។